**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣២ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

លិខិតចូល
ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ2010

# ប្រកាស

## ស្ដីពី ការបង្កើតការិយាល័យ

## គ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ

## និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

## នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយ ប្រើច្បាប់ស្ដីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ ២០អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែម និងការកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤.អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០០៩ លើលិខិតលេខ ១១៦៨ សហវ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៩ ស្ដីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និង ទិញ-លក់ ទ្រព្យបញ្ចាំ
- យោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ លើលិខិតលេខ ០៨២ សហវ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ស្ដីពីការគ្រប់គ្រង ការត្រួតពិនិត្យ និងការផ្ដល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្ដីពីការកែសម្រួល ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ៈ** បង្កើតការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគ ដោយអនុប្បទាន នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ។

ការិយាល័យនេះ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

**ប្រការ២ៈ** តួនាទី និងភារកិច្ចរបស់ការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្ម ទទួលប្រាតិភោគដោយអនុប្បទានមានដូចតទៅ :

- រៀបចំលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។
- រៀបចំបែបបទផ្ដល់ ឬដកហូត ឬព្យួរទុកអាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និង អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។
- ត្រួតពិនិត្យតាមដាន និងជំរុញការអនុវត្តនូវរាល់បណ្ដាវិធានការ បទបញ្ញត្តិ លិខិតបទដ្ឋាននានា ដែល ពាក់ព័ន្ធអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។
- ជំរុញ និងបង្កើនការប្រមូលចំណូលជូនរដ្ឋពីអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្ម ទទួលប្រាតិភោគដោយអនុប្បទាន។
- តាមដាន និងជំរុញអោយអ្នកប្រកបអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួល ប្រាតិភោគដោយអនុប្បទានទាំងអស់ បង់ចំណូលកាតព្វកិច្ចជូនរដ្ឋអោយទាន់ពេលវេលាទៅតាមការកំណត់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ត្រួតពិនិត្យលើបញ្ជីគណនេយ្យ និងឯកសារផ្សេងៗទៀតរបស់អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ក្នុងករណីមានភាពមិនប្រក្រតីក្នុងប្រតិបត្តិការអាជីវកម្ម ។
- ចុះត្រួតពិនិត្យដោយផ្ទាល់អំពីសភាពការណ៍អាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីធ្វើសេចក្តីរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ។
- បោះពុម្ពផ្សាយព័ត៌មានដែលប្រមូលបាន សំដៅថានាគម្នាភាពទីផ្សារអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន លើកលែងតែព័ត៌មានណាដែលការិយាល័យយល់ឃើញថាជាព័ត៌មានសំងាត់ ឬជាព័ត៌មានដែលធ្វើអោយប៉ះពាល់ដល់ទីផ្សារបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ។
- ធ្វើកិច្ចសហការជាមួយអង្គភាពនៃបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ក្នុងករណីដែលអ្នកប្រកបអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន អនុវត្តមិនបានត្រឹមត្រូវតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋាន និង ក្រសួងប្រគល់អោយ
- ធ្វើរបាយការណ៍ប្រចាំខែ រួចបញ្ជូនទៅការិយាល័យរដ្ឋបាល ដើម្បីសរុបជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងថ្នាក់ដឹកនាំក្រសួង ។

**ប្រការ៣:** ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬអង្គភាពជំនាញដ៏ទៃទៀត ប្រធាននាយកដ្ឋានត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធនោះ ដើម្បីសុំគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង រួមគ្នាដោះស្រាយ ។

**ប្រការ៤:** អគ្គលេខាធិការ នាយខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្ត តាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
" ដើម្បីជូនជ្រាបជាព័ត៌មាន "
- ដូចប្រការ ០៤ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ